# អ្នកនាំសារ

The Messenger

38

ខែកញ្ញា ឆ្នាំ២០០៦- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ



## ជីវិតរស់នៅពឹងផ្អែកលើគំនរសំរាម !




យុវជនជាក្តីសង្ឃឹមនៃគ្រួសារក្នុងទ្វីបអាស៊ី
ទំព័រ ៦



មណ្ឌលថែទាំកុមាររបស់ព្រះសហគមន៍
ទំព័រ ១១

សេចក្តីវេទនានៃមនុស្សគឺគ្មានព្រំដែនកំណត់
ទំព័រ ១២

## សំនួរក្មេងៗ

### ព្រះយេស៊ូត្រាស់ហៅលោកសាខេ




ប្អូនធ្លាប់ឮរឿងព្រះយេស៊ូត្រាស់ហៅលោកសាខេនេះដែរឬទេ? តើលោកសាខេជានរណា?

បើតាមគម្ពីរ លោកសាខេជាមេអ្នកទារពន្ធនៅក្នុងក្រុងយេរីខូ។ ជាធម្មតា អ្នកទារពន្ធនៅសម័យព្រះយេស៊ូ គេចាត់ទុកថាមនុស្សបាប ព្រោះអ្នកទាំងនោះទារពន្ធពីប្រជាជនលើសកម្រិតដែលរដ្ឋកំណត់។ គេធ្វើបាបអ្នកក្រីក្រ ដែលគ្មានលុយបង់យ៉ាងធ្ងន់ធ្ងរ។

**តើព្រះយេស៊ូត្រាស់ហៅលោកសាខេយ៉ាងដូចម្ដេច?**

ពេលព្រះយេស៊ូយាងមកដល់ទីក្រុងយេរីខូ។ លោកសាខេចង់ឃើញព្រះអង្គណាស់។ តែលោកមើលមិនឃើញទេ ដោយសារមានមនុស្សច្រើនពេក និងលោកមានមាឌតូច និងកម្ពស់ទាបផង។ ដូច្នេះលោករត់ទៅខាងមុខ ហើយឡើងដើមឈើមួយដើមតាមផ្លូវដែលព្រះអង្គត្រូវយាងកាត់។ ពេលព្រះយេស៊ូយាងទៅដល់កន្លែងនោះ ព្រះអង្គងើយព្រះភ័ក្ត្រឡើងមើលលោកសាខេ ហើយហៅលោកចុះដោយមានបន្ទូលថា: "លោកសាខេអើយ សូមអញ្ជើញចុះមកជាប្រញាប់ ដ្បិតថ្ងៃនេះ ខ្ញុំត្រូវស្នាក់នៅផ្ទះលោក"។ ពេលនោះលោកសាខេត្រេកអរខ្លាំងណាស់ ហើយប្រញាប់ប្រញាល់ទទួលព្រះយេស៊ូទៅផ្ទះលោក។ ពេលព្រះយេស៊ូកំពុងបរិភោគជាមួយលោកសាខេ រួមនិងអ្នកទារពន្ធផ្សេងៗទៀត មនុស្សជាច្រើនរអ៊ូរទាំថា: "អ្នកនេះបរិភោគអាហារជាមួយអ្នកបាប"។

**តើលោកសាខេឆ្លើយដូចម្ដេច?**

ព្រះអម្ចាស់! ខ្ញុំនឹងចែកទ្រព្យសម្បត្តិចំនួនពាក់កណ្ដាលជូនអ្នកក្រីក្រ បើខ្ញុំទារពន្ធលើសកំនត់ ខ្ញុំសងវិញមួយជាបួន។ ព្រះយេស៊ូឆ្លើយតបថា ការសង្គ្រោះបានមកដល់ផ្ទះនេះហើយ។

លី សុវណ្ណា

## អធិប្បាយព្រះបន្ទូល

### ថ្ងៃទី ០៣ កញ្ញា ២០០៦ ត្រូវនឹងថ្ងៃអាទិត្យទី ២២ ប្រចាំឆ្នាំ "ខ"

#### "មានតែអ្វីៗ ចេញពីមនុស្សប៉ុណ្ណោះ ដែលធ្វើឱ្យមនុស្សមិនបរិសុទ្ធ"

(ម៉ាកុស ៧,១-៨. ១៤-១៥. ២១-២៣)

ពួកផារីស៊ីជាអ្នកកាន់តាមធម្មវិន័យនៃលោកម៉ូសេយ៉ាងតឹងរ៉ឹង និងបង្កើតវិន័យជាច្រើន ដោយស្មានថាអ្នកធ្វើតាមវិន័យទាំងនេះពិតជាមានបុណ្យ និងទទួលការសង្គ្រោះ។ ដូចគេធ្លាប់ធ្វើពិធីជម្រះដៃ ជម្រះខ្លួន ជម្រះឆ្នាំង ចាន និងតុទូជាដើម ក្រោយពេលគេមកពីផ្សារវិញ។ គេធ្វើដូច្នេះ ពុំមែនមកពីចង់បានអនាម័យទេគឺមកពីគេចង់ជម្រះខ្លួនពីសេចក្ដីសៅហ្មងនានាដែលមាន ព្រោះបានទាក់ទងជាមួយសាសន៍ដទៃ។ គេភ្លេចសេចក្ដីសំខាន់ជាងគេក្នុងគ្រប់សាសនា គឺឱ្យមនុស្សមានចិត្តទៀងត្រង់បរិសុទ្ធ។ គ្រិស្តបរិស័ទជាច្រើន សូម្បីបព្វជិត និងបូជាចារ្យខ្លះក៏ចូលចិត្តកាន់ប្រពៃណីយ៉ាងតឹងរ៉ឹងដូចគេដែរ។ ថ្ងៃនេះ ព្រះយេស៊ូរំឭកអំពីសេចក្ដីដ៏សំខាន់ជាងគេ គឺថាយើងត្រូវមានចិត្តទៀងត្រង់ និងចិត្តស្រឡាញ់!។ វិន័យ ឬប្រពៃណីផ្សេងៗ គ្រាន់តែជាទម្លាប់ដែលមនុស្សបង្កើត។ យើងគួរគោរពទុកជាកេរពីដូនតាមក



តែការកាន់ប្រពៃណីពុំអាចធ្វើឱ្យបានបុណ្យទេ។ យើងត្រូវនឹកពាក្យទូន្មាន សន្តអូគូស្ទាំង ដែលថា: "អ្នកចង់ធ្វើអ្វី ក៏ធ្វើទៅ តែត្រូវមានចិត្តស្រឡាញ់យ៉ាងពិតប្រាកដ!។ សេចក្ដីស្រឡាញ់ជាគ្រឹះសេរីភាពរបស់គ្រិស្តបរិស័ទ។ គ្រិស្តទូតប៉ូលថែងថា: "ព្រះគ្រិស្តបានរំដោះយើងឱ្យមានសេរីភាពពិតប្រាកដ... ប៉ុន្តែសូមកុំយកសេរីភាពនេះធ្វើជាលេសដើម្បីរស់នៅតាមលោកីយ៍ឱ្យសោះ ផ្ទុយទៅវិញត្រូវបម្រើគ្នាទៅវិញទៅមកដោយចិត្តស្រឡាញ់" (កាឡ ៥,១-១៣)។

### ថ្ងៃទី ១០ កញ្ញា ២០០៦ ត្រូវនឹងអាទិត្យទី ២៣ ប្រចាំឆ្នាំ "ខ"

#### "ចូរបើកឡើង!"

(ម៉ាកុស ៧,៣១-៣៧)

ព្រះរាជកិច្ចរបស់ព្រះយេស៊ូ សុទ្ធសឹងជាសញ្ញាសម្គាល់បញ្ជាក់ពីបេសកកម្មនៃព្រះគ្រិស្តក្នុងលោកនេះ។ មានមនុស្សខ្លះគថ្លង់តាមធម្មជាតិពីកំណើតមក។ មានមនុស្សខ្លះរស់នៅដូចជាមនុស្សគថ្លង់ដែរ គឺយើងទាំងអស់គ្នាជាមនុស្សគថ្លង់។ តែព្រះយេស៊ូអាចប្រោស ឱ្យស្ដាប់ឮ និងនិយាយបាន។ ព្រះជាម្ចាស់មានបន្ទូលមកយើងជារៀងរាល់ថ្ងៃតាមរយៈអ្នកដទៃ តាមប្ដីប្រពន្ធ កូនយើង អ្នកជិតខាង គ្រិស្តបរិស័ទក្ដី ពុទ្ធបរិស័ទក្ដី តែយើងពុំសូវមានចិត្តចង់ស្ដាប់ព្រះសូរសៀងនៃព្រះជាម្ចាស់តាមគេទេ ដោយយើងស្មានថា ព្រះអង្គមានបន្ទូលមកយើងតែតាមព្រះគម្ពីរ តាមបូជាចារ្យ ឬតាមបព្វជិតប៉ុណ្ណោះ។ យើងត្រូវតែសូមអង្វរព្រះយេស៊ូ ដើម្បីឱ្យព្រះអង្គបើកត្រចៀកយើង ឱ្យចេះស្ដាប់ព្រះសូរសៀងរបស់ព្រះអង្គ។ ជួនកាលយើងជាមនុស្សគដែរ គឺមិនព្រមស្ដាប់អ្នកដទៃ ប្ដីប្រពន្ធកូនយើង ឬអ្នកដែលជំទាស់នឹងយើង។ យើងដូចជាមនុស្សគដ៏អាក្រក់ជាងមនុស្សគពីធម្មជាតិ ដែលបណ្ដាលឱ្យមានក្ដីស្អប់រីតតែខ្លាំងឡើងៗ។ ពេលមានពិធីចូលព្រះសហគមន៍ បូជាចារ្យគូសសញ្ញាឈើឆ្កាងលើត្រចៀក និងបបូរមាត់យើង ដូចព្រះយេស៊ូបានប្រព្រឹត្តចំពោះអ្នកគថ្លង់។ នៅពេលមុនទទួលអគ្គសញ្ញាជ្រមុជទឹក បូជាចារ្យគូសសញ្ញាឈើ



ឆ្កាងលើបបូរមាត់ និងត្រចៀកយើង រួចពោលពាក្យ របស់ព្រះយេស៊ូទៀតគឺ "ចូរបើកឡើង"។ បើព្រះសហគមន៍ធ្វើសញ្ញាសម្គាល់នេះ ២ដង ឱ្យយើងមានន័យថា សញ្ញានេះមានសារៈសំខាន់ណាស់!។ រៀងរាល់ថ្ងៃ យើងត្រូវអង្វរព្រះយេស៊ូ សូមព្រះអង្គប្រោសប្រណីឱ្យយើង អាចស្ដាប់ព្រះអង្គ មានព្រះបន្ទូលមកយើង និងឱ្យយើងអាចនិយាយទៅរកអ្នកដទៃដែរ។



### ថ្ងៃទី ១៧ កញ្ញា ២០០៦ ត្រូវនឹងអាទិត្យទី ២៤ ប្រចាំឆ្នាំ "ខ"

#### "ចុះអ្នកវិញ តើអ្នកថា ខ្ញុំជានរណាដែរ?"

(ម៉ាកុស ៨,២៧-៣៥)

ថ្ងៃនេះព្រះយេស៊ូសួរយើងម្នាក់ៗ ថា "តើអ្នករាប់រកខ្ញុំទុកជានរណា?"។ ប្រហែលបងប្អូនឆ្លើយថា ព្រះអង្គជាបរមគ្រូ ដែលប្រៀនប្រដៅមនុស្ស ដូចព្យាការីមួយរូប ឬដូចព្រះពុទ្ធដែរ។ ប្រហែលម្នាក់ទៀតថា ព្រះអង្គជារៀមច្បង ជាមិត្តសំឡាញ់ ឬជាស្វាមីខ្លួន។ ម្នាក់ទៀតនិយាយតាមគម្ពីរថា ព្រះអង្គគឺជា "ព្រះបុត្រារបស់ព្រះជាម្ចាស់"។ ពាក្យទាំងនេះសុទ្ធតែត្រឹមត្រូវល្អណាស់ យើងក៏គួរអធិដ្ឋានដោយរៀបរាប់ព្រះនាមទាំងអស់របស់ព្រះយេស៊ូដែលមានចែងក្នុងគម្ពីរ ជាពិសេសក្នុងគម្ពីរលោកយ៉ូហាន។ ថ្ងៃនេះព្រះយេស៊ូរំឭកយើងអំពីអត្ថន័យព្រះនាម "ព្រះគ្រិស្ត"។ ជនជាតិយូដាតែងហៅព្រះមហាក្សត្ររបស់គេថា "ព្រះគ្រិស្ត" គឺអ្នកដែលត្រូវគេចាក់ប្រេងអភិសេក។ តាំងពីពេលពួកគេជាប់ជាឈ្លើយមក គេអស់ព្រះមហាក្សត្រ ទើបនាំគ្នារង់ចាំស្ដេចដ៏អស្ចារ្យមួយអង្គ ដែលនឹងរំដោះស្រុកគេ និងធ្វើឱ្យព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់កាលពីមុនៗមកកើតជារូបរាង។ គេរង់ចាំព្រះគ្រិស្តទុកជាស្ដេចដែលអាចប្រទានសេចក្ដីសុខសាន្តគ្រប់យ៉ាងឱ្យគេ។



កាលព្រះយេស៊ូសួរ លោកសីលាឆ្លើយភ្លាម: "លោកជាព្រះគ្រិស្ត!" លោកស្មានថា លោកយេស៊ូនេះនឹងនាំសេចក្ដីសុខសាន្តតាមផ្លូវលោកដល់ប្រជាជនអ៊ីស្រាអែល។ តែព្រះយេស៊ូបង្ហាញផ្លូវ ព្រះអង្គនាំសេចក្ដីសុខសាន្តនោះ គឺព្រះអង្គត្រូវរងទុក្ខនឹងត្រូវគេធ្វើគុតយ៉ាងសែនអាម៉ាស់។ នៅថ្ងៃនេះ យើងម្នាក់ៗ ត្រូវសួរខ្លួនឯងថា តើព្រះយេស៊ូនាំសេចក្ដីសុខយ៉ាងណាឱ្យខ្ញុំ?

### ថ្ងៃទី ២៤ កញ្ញា ២០០៦ ត្រូវនឹងអាទិត្យទី ២៥ ប្រចាំឆ្នាំ "ខ"

#### "ពេលដើរតាមផ្លូវ តើអ្នកនិយាយអំពីរឿងអ្វី?"

(ម៉ាកុស ៩,៣០-៣៧)

ថ្ងៃនេះ ព្រះយេស៊ូសួរយើងម្នាក់ៗថា "ពេលដើរតាមផ្លូវមកព្រះវិហារ តើអ្នកនិយាយពីរឿងអ្វី?"។ តើយើងតបឆ្លើយយ៉ាងណា? យើងតែងនិយាយអំពីរឿងចង់បានលុយ រឿងស្នេហា ចង់ឈ្នះគេ ចង់សងសឹកគេ ឬនិយាយដើមគេ។ល។ យើងគួររិះគិតឱ្យមែនទែនពីពាក្យដែលយើងនិយាយរាល់ថ្ងៃ។ ព្រះយេស៊ូទើបនឹងមានព្រះបន្ទូលអំពីរបៀបព្រះអង្គ ជាព្រះគ្រិស្ត គឺព្រះអង្គត្រូវរងទុក្ខដោយគេធ្វើគុតយ៉ាងសែនអាម៉ាស់ តែសាវ័កពុំយល់ទាល់តែសោះ គេគិតតែពីចង់បានអំណាច មុខមាត់ និងកន្លែងកិត្តិយសក្នុងព្រះរាជាណាចក្រ។ ព្រះយេស៊ូយកកូនក្មេងធ្វើជាគំរូ ដើម្បីបង្ហាញអំពីចិត្តនៃគ្រិស្តបរិស័ទ។ ចំពោះយើងជាគ្រិស្តបរិស័ទ យើងជឿថា អ្នកធំជាងគេ គឺអ្នកតូចជាងគេ និងអ្នកបម្រើគេ។ សេចក្ដីនេះផ្ទុយពីបំណងមនុស្សទូទៅ។ បើបងប្អូនចង់ធ្វើជាមិត្តនឹងព្រះយេស៊ូ ចូរមានចិត្តគំនិតដូចព្រះអង្គ ចូររស់នៅឱ្យបានដូចព្រះអង្គ គឺសុខចិត្តធ្វើជាអ្នកតូច និងបម្រើគេ ដូចព្រះយេស៊ូ ដែលបម្រើគេ លាងជើងគេ និងបូជាជីវិតដើម្បីជាប្រយោជន៍គេដែរ។ឧបមាបងប្អូនជាឪពុកម្ដាយដែលមានកូន បងប្អូនមានអំណាចលើកូន តែត្រូវសួរខ្លួនឯងម្នាក់ៗសិនថា តើខ្ញុំប្រើអំណាចនេះយ៉ាងណាដើម្បីបម្រើប្រយោជន៍ពិតប្រាកដ



របស់កូនឱ្យវាចម្រើនឡើងក្នុងគ្រប់វ័យ? ខ្ញុំជាមន្ត្រីរាជការ មានអំណាច តើខ្ញុំប្រើអំណាចរបស់ខ្ញុំរបៀបណាដើម្បីបម្រើអ្នកដែលខ្វះខាតជាងគេ? បើខ្ញុំជាអ្នកមាន ជាការល្អហើយ តើខ្ញុំយកធនធានរបស់ខ្ញុំតាមរបៀបណាដើម្បីបម្រើអ្នកក្រីក្រជាងគេ?

**សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា!**



### ថ្ងៃទី២២ ខែកញ្ញា ២០០៦ ភ្ជុំបិណ្ឌ!

គ្រិស្តបរិស័ទខ្មែរ ក៏ដូចប្រជាជនកម្ពុជាទូទាំងប្រទេស យកចិត្តទុកដាក់ប្រារព្ធពិធីភ្ជុំបិណ្ឌ ជាប្រពៃណីខ្មែរពីបុរាណ។ តាមពិតយើងមិនដាក់បិណ្ឌតាមវេន ហើយយើងក៏មិនប្រជុំវេនទាំងអស់នៅថ្ងៃទី ១៥ រោច ខែភទ្របទ ដូចពុទ្ធបរិស័ទទេ ប៉ុន្តែយើងសម្ដែងសេចក្ដីនឹករឭក និងកតញ្ញូតាធម៌ចំពោះវិញ្ញាណក្ខន្ធមាតាបិតា ដូនតា គ្រូបាធ្យាយ និងអ្នកមានគុណលើយើង។ យើងមិនទៅប្រាំពីរវត្តតាមប្រពៃណីខ្មែរ ដាក់ម្ហូបអាហារថ្វាយដូនតាសេពសោយទេ តែយើងសូមអរព្រះគុណព្រះជាម្ចាស់ជាប្រភពនៃជីវិតគ្រប់យ៉ាង ដែលទ្រង់បានបន្តព្រះជន្មផ្ទាល់របស់ព្រះអង្គមកកាន់យើងដោយសារដូនតាទាំងនោះ។ យើងមិនខ្លាចវិញ្ញាណក្ខន្ធដូនតាទេ ផ្ទុយទៅវិញយើងស្រឡាញ់ និងអរគុណគាត់។ យើងជាគ្រិស្តបរិស័ទជឿថា វិញ្ញាណក្ខន្ធដូនតា គ្រូបាធ្យាយ អ្នកមានគុណលើយើង សព្វថ្ងៃមានជីវិតរួមជាមួយព្រះបិតា ទោះបើគាត់ជាពុទ្ធបរិស័ទក៏ដោយ ព្រោះមានព្រះជាម្ចាស់តែមួយព្រះអង្គប៉ុណ្ណោះ ជាព្រះបិតារបស់មនុស្សទាំងអស់។ ដូច្នេះយើងក៏អាចសូមឱ្យដូនតា គ្រូបាធ្យាយ អ្នកមានគុណលើយើង ជួយយើងក្នុងពេលនេះ ឱ្យបានសេចក្ដីសុខ ឱ្យប្រទេសយើងចម្រុងចម្រើន មានយុត្តិធម៌ និងមានសន្តិភាព។

បូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងសូដ៏

# យុវជនជាក្ដីសង្ឃឹម នៃគ្រួសារក្នុងទ្វីបអាស៊ី

The 4th Asian Youth Day 2006 HONG KONG

**នេះគឺជាប្រធានបទថ្មីសម្រាប់យុវជនកម្ពុជាក៏ដូចជាយុវជនមកពីប្រទេសនានា ក្នុងទិវាយុវជនអាស៊ី ដែលរួមមានបណ្ដាប្រទេសនៅអាស៊ី ចំនួន២២ប្រទេស ប្រទេសនៅអឺរ៉ុប៣ ដែលមានមនុស្សទាំងអស់ប្រមាណជា ១ពាន់នាក់ មកចូលរួម។**

យុវជន យុវនារី ដែលតំណាងព្រះសហគមន៍កាតូលិកនៅកម្ពុជាចំនួន៩នាក់ដឹកនាំដោយលោកបូជាចារ្យអេនរីកូ អ្នកទទួលខុសត្រូវមណ្ឌលនិស្សិតភ្នំពេញ និងកញ្ញាវ៉ុនឌី សមាជិកកាតូលិកហុងកុង បានទៅ ហុងកុង ចូលរួមទិវាយុវជនអាស៊ី កាលពីថ្ងៃទី២៨ កក្កដា ដល់ថ្ងៃទី៩ សីហា។ លោកបូជាចារ្យអេនរីកូមានប្រសាសន៍ថា : "ទិវាយុវជនអាស៊ី មានគោលបំណងមួយពិសេស គឺចង់ជួបប្រជុំនិងប្រមូលយុវជន-នារី កាតូលិកទាំងអស់ នៅទ្វីបអាស៊ី ដើម្បីរិះគិតពិចារណាអំពីលក្ខណៈពិសេសជាកាតូលិកក្នុងទ្វីប ដែលឱ្យកំណើតនូវសាសនាធំៗជាងគេ ក្នុងពិភពលោក"។

ក្នុងទិវានោះ លោកបូជាចារ្យសង្កេតឃើញយុវជនកម្ពុជា បានទទួលការយល់ដឹងច្រើនអំពីបទពិសោធន៍នៃ ព្រះសហគមន៍ប្រទេសដទៃៗ ទំនៀមទម្លាប់ប្រពៃណី និងជីវភាពរស់នៅរបស់គ្រួសារហុងកុង។ ម្យ៉ាងទៀតពួកគេមានអារម្មណ៍ថា ទោះបីពួកគេមកពីប្រទេសឬកន្លែងផ្សេងគ្នាក្ដី តែពួកគេនៅជាគ្រួសារតែមួយ ក្នុងព្រះនាមព្រះយេស៊ូ មានជំនឿតែមួយ។ ពិសេសនោះ ពួកគេបានជួបយុវជន ដែលបានរៀបចំនូវការប្រជុំឱ្យមានលក្ខណៈល្អត្រឹមត្រូវ និងម៉ឺងម៉ាត់។ យុវជន៩នាក់ ដែលទៅចូលរួមមានសេរីភាពទំនាក់ទំនងជាមួយយុវជន គ្រប់ប្រទេស និងគ្រប់ជាតិសាសន៍។ ក្នុងរយៈពេល ១៤ថ្ងៃ ដែលពួកគេនៅទីនោះ ពុំមានបញ្ហាអ្វីឡើយ។

ប្រទេស ដែលបានរៀបចំ ទិវាយុវជនអាស៊ីនេះ លើកទី១ គឺប្រទេសថៃ ទី២ តៃវ៉ាន់ ទី៣ ប្រទេសឥណ្ឌា និងទី៤ គឺហុងកុង។

ក្នុងទិវាយុវជនអាស៊ីនេះ មានការប្រជុំមួយទៀត ដែលហៅថា កិច្ចប្រជុំប្រធានយុវជនអាស៊ី AYMM ដែលមានការចូលរួមពីលោកបូជាចារ្យ បងស្រី បងប្រុស និងយុវជនមួយចំនួនតូច។ កិច្ចប្រជុំនេះមានគម្រោងការ ២ ទី១ គួរមានការិយាល័យពិសេសមួយ ដែលអាចរៀបចំរាល់សកម្មភាពសម្រាប់ យុវជន យុវនារីកាតូលិកនៅកម្ពុជា ជាពិសេស ជួយរិះគិតពិចារណាអំពីគម្រោងការ អប់រំជំនឿចំពោះយុវជនក្រោយពេលជ្រមុជទឹក។ ទី២ ដើម្បីឱ្យមានការិយាល័យនេះ យើងសំណូមពរឱ្យលោកអភិបាល ឱ្យជ្រើសរើសយុវជន ៣-៤នាក់ ដែលស្រលាញ់ និងចង់ជួយព្រះ-សហគមន៍។លោកបូជាចារ្យគិតថាគម្រោងនេះអាចនឹងសម្រេចបាននាពេលអនាគត។

មុំ គន្ធា


Photo: Ran




Photo: CCSC

## លោកប្រេម សំណាង:

ខ្ញុំទទួលបានបទពិសោធន៍ជំនឿដ៏រឹងមាំសម្រាប់ជីវិតវប្បធម៌ថ្មី និងសេចក្ដីស្រលាញ់ថ្មី។ នេះជាឱកាសដែលធ្វើឱ្យខ្ញុំយល់ថា យុវជនត្រូវតែមានសេចក្ដីសង្ឃឹម។ ជីវិតរបស់ខ្ញុំនឹងបានល្អប្រសើរតាមរយៈការប្រជុំនេះ។ ខ្ញុំនឹងចែករំលែកចំពោះគ្រួសារ មិត្តភក្ដិ និងមនុស្សជាច្រើនទៀត។ ទាំងអស់នេះធ្វើឱ្យខ្ញុំយល់ច្បាស់អំពីសេចក្ដីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក។

## កញ្ញាម៉ៅ ដារី:

បន្ទាប់ពីចូលរួមពិភាក្សាចែករំលែកបទពិសោធន៍ជាមួយគ្នាមក នាងខ្ញុំយល់ថា គ្រប់ជាតិសាសន៍មានបញ្ហាស្ទើរតែដូចគ្នា មានសេចក្ដីស្រលាញ់ និងសេចក្ដីសង្ឃឹមក៏ដូចគ្នា។ ទាំងនេះទាក់ទងនឹងជំនឿ បើយើងគ្មានជំនឿ យើងមិនអាចសម្រេចនូវគោលការអ្វីមួយបានឡើយ។ សេចក្ដីសង្ឃឹមបានពីជំនឿ។ ជំនឿបានពីការអធិដ្ឋាន និងទុកចិត្តលើព្រះជាម្ចាស់។

## លោកសន សារឿន:

អ្វីដែលខ្ញុំទទួលបានពីការប្រជុំនេះ គឺបទពិសោធន៍ល្អៗទាក់ទងនឹងជំនឿសាសនា អរិយធម៌ ទំនៀមទម្លាប់ និងរបៀបរស់នៅនៃប្រទេសនីមួយៗនៅទ្វីបអាស៊ី។ ជាពិសេស ប្រធានបទនៃការប្រជុំផ្ដោតសំខាន់ គឺទាក់ទងនឹងយុវជនដែលដើរតួសំខាន់ក្នុងសង្គម ព្រះសហគមន៍ និងក្នុងគ្រួសារ។ យុវជនជាអ្នកនាំក្ដីសង្ឃឹម ក្ដីស្រលាញ់ និងសក្ខីភាពខាងជំនឿសម្រាប់ព្រះសហគមន៍ និងសម្រាប់គ្រួសារ។





## សាលាដុនបូស្កូនារីនៅ ទួលគោកជ្រើសរើសសិស្សថ្មី

កាលពីព្រឹកថ្ងៃទី៣០ សីហា យុវតីជាច្រើនមកពីខេត្តនានា ប្រមាណជាជិត ៣០០នាក់ បានឈរបន្តគ្នាជាជួរៗ ក្នុងដៃម្នាក់ៗ មានកាន់លេខរៀងរង់ចាំការហៅឈ្មោះដើម្បីចូលទៅបំពេញសំណុំបែបបទសុំចូលរៀនក្នុងសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈដុនបូស្កូនារីនៅទួលគោកផ្នែកលេខាធិការិនី ដែលរៀនរយៈពេល២ឆ្នាំ។

យុវតីទើបនឹងបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ស៊ឹម សុរិយស៊ុំ បាននិយាយថា នាងដាក់ពាក្យចង់រៀននៅសាលាដុនបូស្កូ គឺដោយសារនាងបានឃើញសេចក្ដីប្រកាស និងការផ្ដល់ព័ត៌មានតាមរយៈមិត្តភក្ដិ ហើយនាងស្គាល់កូនសិស្សដែលបានរៀននៅសាលានេះ និយាយសរសើរប្រាប់ថា សាលាហ្នឹងល្អ មានវិន័យត្រឹមត្រូវ មិនដូចការប្រឡងនៅខាងក្រៅទេ។ រីឯកញ្ញាសុភ័ណ្ឌ សម្បុរខ្មៅស្រអែម មកពីខេត្តកណ្ដាល បានបង្ហាញអារម្មណ៍យ៉ាងនេះថា: "ខ្ញុំមានអារម្មណ៍ភ័យផងអរផង ប្រសិនបើប្រឡងជាប់ ប្រាកដជាអរមែនទែន"។ នាងបន្តដោយលើកសរសើរពីសាលានេះ ចំពោះការលើកកម្ពស់តម្លៃនៃការសិក្សារបស់ស្ត្រី។ នាងយល់ឃើញថា ភាគច្រើន នារីមិនទាន់រៀនបានដល់ថ្នាក់ទី១២ផង ក៏ឈប់រៀន ចូលធ្វើការនៅរោងចក្រទៅហើយ។

ការជ្រើសរើសសិស្សថ្មីនេះ មានរយៈពេល៣ ទៅ៤ថ្ងៃ ដោយមានការប្រឡងសំនួរសរសេរ និងធ្វើសម្ភាសន៍។ ចំពោះលក្ខខណ្ឌ គឺយុវនារីត្រូវមានកម្រិតវប្បធម៌ត្រឹមថ្នាក់ទី១២ ជាប់ ឬធ្លាក់បាក់ឌុប ជាអ្នកក្រីក្រ។ សាលានេះស្ថិតនៅផ្ទះលេខ៦០ ផ្លូវ៣១៥ រាជធានីភ្នំពេញ។

កែវ កញ្ញា


យុវតីកំពុងទិញដីម៉ង់ចូលរៀន

Photo: K. Kagha


ព្រះវិហារបាត់ដំបងមុនទសវត្សរ៍ទី៧០

Photo: MEP

៧០ឆ្នាំ

## ស្ថិតិគ្រិស្តបរិស័ទនៃភូមិភាគបាត់ដំបង

ភូមិភាគបាត់ដំបង មានព្រះសហគមន៍ចំនួន២៥ និងមានគ្រិស្តបរិស័ទ សរុបចំនួន ៣៤៥០នាក់ រួមទាំងអ្នកស្វែងរក។ ក្នុងនោះមានដូចជា:

ព្រះសហគមន៍ បាត់ដំបងក្រុង កើតនៅក្នុងឆ្នាំ ១៧៩០ ពេលនេះ មាន គ្រិស្តបរិស័ទ (គ្រិ) ៤០៤នាក់ ជំហាន់ទី១=១៩នាក់។ តាហែន គ្រិ ៨៧នាក់ ជំហានទី១=១៥នាក់ និងស្វែងរក ៩៥នាក់។ ច្រាបវ៉ាល គ្រិ ៣៥នាក់ ជំហានទី១=១២នាក់ និងស្វែងរក ៨នាក់ ។ តាពូង គ្រិ ៨២នាក់ ជំហានទី១=១៥ នាក់ និងស្វែងរក ១២នាក់។ ខ្នាចរមាស គ្រិ ៣១នាក់ និងស្វែងរក ៣៣នាក់។ និគម គ្រិ ១៨នាក់ និងស្វែងរក ២៧។ ចំណោម គ្រិ ៣២៧ រួមទាំងស្វែងរក និងជំហានទី១។ ប៉ោយប៉ែត គ្រិ ៨២នាក់ និងស្វែងរក ៩១។ ស្វាយស៊ីសូផុន គ្រិ ៤០នាក់ និងស្វែងរក ១២។ សៀមរាប គ្រិ ១៩៦នាក់ ជំហានទី១=៨ និងស្វែងរក ៥៧។ ចុងឃ្នាស គ្រិ ១២នាក់ ជំហានទី ១=ម្នាក់ និងស្វែងរក ៣០។ តាអំ គ្រិ ១៥នាក់ និងស្វែងរក ៨។ ព្រែកទាល់ គ្រិ ម្នាក់ និងស្វែងរក ៤០។ ប៉ៃលិន គ្រិ ៣០នាក់ ជំហានទី១=៩ និងស្វែងរក ៥។ កំពង់គោក្រោម គ្រិ ១៧៧នាក់ ជំហានទី១=៧ និងស្វែងរក ១៣០។ ព្រែកស្បូវ គ្រិ ៩៧នាក់ ជំហានទី១=៣ និងស្វែងរក ៦០។ កំពង់រទេះ គ្រិ ៥៧នាក់ ជំហានទី១=១៥ និងស្វែងរក ២០។ បល្ល័ង្គ គ្រិ ៣២នាក់។ ម្ខាវ គ្រិ ៣៥នាក់ និងស្វែងរក ១៥។ តាំងគោក គ្រិ ១០នាក់ ជំហានទី១=៥ និងស្វែងរក ១៥។ ភូមិប៉ាង គ្រិ ៨នាក់ និងស្វែងរក ១០។ ពោធិ៍សាត់ គ្រិ ២១២នាក់ ជំហានទី១=២ និងស្វែង រក ១៩។ កំពង់ហ្លួង គ្រិ ២៨៩នាក់ និងស្វែងរក ៥។ ឆ្នុកទ្រូ គ្រិ ២២៩នាក់ និងស្វែងរក ៣០។ កំពង់ឆ្នាំង គ្រិ ១៥៧នាក់ ជំហានទី១=៣ និង ស្វែងរក ១៦។

លី សុវណ្ណា

ជីវភាពរបស់មនុស្សម្នាក់ៗមានសារៈសំខាន់ណាស់។ មនុស្សខំធ្វើអ្វីៗទោះស្រួល ឬលំបាកក៏ដើម្បីឱ្យមានជីវិតរស់នៅស្រួល។ អ្នកខ្លះកើតមកលើត្រកូលដែលមានទ្រព្យសម្បត្តិសម្បូរសប្បាយ មានកិត្តិយស មានសេចក្ដីស្រឡាញ់ពីអ្នកដទៃច្រើន ប៉ុន្តែបើក្រលេកមើលអ្នកខ្លះទៀតកើតមកភ្លាមជួបតែបញ្ហា រងទុក្ខវេទនា គ្មានអ្នករាប់អាន ជាពិសេសទទួលការមើលងាយ មើលថោកពីអ្នកមួយចំនួនថែមទៀត។ ប៉ុន្តែទោះបីជីវិតរបស់ពួកគេមានការលំបាកយ៉ាងណាក៏ដោយ ក៏ពួកគេតស៊ូពុះពារគ្រប់បែបយ៉ាងដើម្បីបន្តជីវិតរបស់ខ្លួនឱ្យបានរស់នៅដូចគេដូចឯងដែរ។
តើជីវិតរបស់ពួកគេត្រូវប្រឈមមុខនឹងការលំបាកយ៉ាងណាខ្លះ ?

# ជីវិតរស់នៅពឹងផ្អែកលើគំនរសំរាម


Photo: L. Sovanna

ប្រជាពលរដ្ឋកំពុងប្រញាយគ្នារើសរករបស់របរសំរាមអេតចាយដែលអាចប្រើប្រាស់បាន ឬយកវាលក់ដើម្បីចិញ្ចឹមជីវិត


Photo: K. Kagha

បើសិនប្រិយមិត្តទាំងឡាយមានចំណាប់អារម្មណ៍ចង់ជជែកពិភាក្សាអំពីអត្ថបទនេះ សូមផ្ញើសំបុត្រមកកាន់ការិយាល័យព្រឹត្តិបត្រ "អ្នកនាំសារ" តាមរយៈលោកឪពុក បងប្រុស-បងស្រីដែលនៅជិតបំផុត។

សម្លេងស្នូរសន្ធឹកឡានបើកចេញចូល និងបណ្ដាក់គ្នាឥតមានម៉ោងសម្រាកមិនថាយប់ ឬថ្ងៃ។ ក្នុងមួយថ្ងៃៗ យ៉ាងហោចណាស់ ក៏មានឡានចេញចូលទីនោះប្រមាណជា ២០០ឡានគ្រប់ពេលវេលា ពីមួយថ្ងៃទៅមួយថ្ងៃ។ ឡានទាំងនោះមិនមែនជាឡានអ្វីផ្សេង ក្រៅពីឡានដឹកសំរាមនោះឡើយ។
ស្រមោលផ្សែងហុយព្រាងៗចេញពីលើភ្នំរួមផ្សំ និងក្លិនស្អុយអសោចភាយពាសពេញបរិវេណដីប្រមាណជា ២គីឡូម៉ែត្រដែលជាគំនរសំរាមពណ៌ខ្មៅយ៉ាងធំ។ សម្លេងហៅកញ្ជ្រៀវខ្សៀវខ្សារ លាយឡំជាមួយនិងសំណើច សើចក្អាកក្អាយ របស់មនុស្សដោយភាពសប្បាយរីករាយហាក់គ្មានគិតព្រួយបារម្ភពីអ្វីដែលនៅជុំវិញពួកគេឡើយ។ មានកូនតូបតូចៗជាច្រើនដែលគ្របដណ្ដប់ដោយតង់ពណ៌ខៀវស្លេកកន្ទេលរហែក និងក្រដាសចាស់ៗ ខ្លះមានជញ្ជាំង ខ្លះមានតែដំបូល ដែលវាធ្វើគ្រាន់តែសម្រាប់បាំងពីកំដៅថ្ងៃ និងភ្លៀងតែប៉ុណ្ណោះ។
តាមបណ្ដោយផ្លូវទៅកាន់ទីលានកណ្ដាល កន្លែងចាក់សំរាមអមដោយអ្នកលក់នំចំណី និងរោមដោយពួករុយក្បាលខៀវរាប់មិនអស់ និងអ្នកកំពុងញ៉ាំដូចជាឆ្ងាញ់ ដោយហាក់ពុំចាប់អារម្មណ៍នឹងក្លិន ឬអ្វីៗ ដែលនៅសងខាងពួកគេឡើយ។

អង្គុយនៅលើសំរាម ទ្រាប់ដោយកំទេចក្រដាសនៅពីក្រោម គឺ អ្នកស្រីភុន ង៉ែត ចំណាយពេលរស់នៅលើភ្នំសំរាមដែលមនុស្សភាគច្រើនមិនដែលបានស្គាល់ ហើយក៏គ្មានបំណងចង់ស្គាល់ផងដែរនោះអស់រយៈពេលជាង ៩ឆ្នាំមកហើយ។ អ្នកស្រីង៉ែត បានឱ្យដឹងថា : "សមាជិកគ្រួសាររបស់ខ្ញុំទាំងអស់ ៨នាក់ ត្រូវមកចាប់អាជីពរើសអេតចាយនេះ គឺមានតែកូនម្នាក់គត់ ដែលមានសំណាងបានទៅសាលារៀនសូត្រ"។ ក្នុងទឹកមុខស្រងូតស្រងាត់ ហើយងើបទៅអង្គុយនៅក្បែរខ្ទមធ្វើពីក្រណាត់តង់ចាស់ៗ ភុន ង៉ែត ជាស្ត្រីមេម៉ាយផងនោះ បានបន្តសំដីរបស់គាត់ទៀតថា ការដែលគាត់សំរេចមករកស៊ីនៅទីនេះ ក៏ដោយសារតែគ្មានការងារអ្វីធ្វើ ហើយមុខរបរដែលគាត់ធ្វើពីមុននោះចេះតែខាតដើម។ ចំណែកមុខរបរប្រភេទនេះគឺជាមុខរបរគ្មានដើម តែវាអាចរកចំណូល ផ្គត់ផ្គង់ក្រុមគ្រួសាររបស់គាត់បាន ប៉ុន្តែបានដោយក្ដីវេទនាបំផុត។
ក្នុងមួយថ្ងៃ អ្នកស្រីរើសអេតចាយនៅលើភ្នំសំរាមនេះ អាចរកចំណូលបានជាមធ្យមពី ៨០០០-១០០០០រៀល។
ស្នូរកញ្ជ្រែកៗ ជាសញ្ញាថា មានឡានថ្មីចូលមកដល់ទៀតហើយ! រំពេចនោះសូរសន្ធឹកសម្លេងឡានពណ៌ខៀវដែលផ្ទុកដោយសំរាមគ្រប់ប្រភេទនៅលាយឡំគ្នា ដែលមានប្រតោងដោយមនុស្សចាស់ក្មេងជាន់ពីលើវា រហូតដល់ទីកន្លែង ដែលសំរាមត្រូវបានចាក់ចោល។ ពួកក្មេង និងមនុស្សចាស់ប្រុសស្រី ដែលតោងឡាននោះ គឺដើម្បីដណ្ដើមយករបស់របរណាដែលពួកគេអាចលក់បាន។ ប្រសិនបើមិនដណ្ដើម ឬក៏រហ័សរហួននោះទេ ប្រាកដជានៅថ្ងៃនេះ គ្មានលុយចាយឡើយ ពីព្រោះ មានមនុស្សច្រើនដែលកំពុងតែប្រវេប្រវាប្រមូលយកអ្វីដែលពួកគេត្រូវការ ដែលនៅទីកន្លែងណាក៏ដោយ យើងធ្លាប់តែឃើញគេដណ្ដើមគ្នាយកលុយកាក់ ឬរបស់មានតម្លៃតែប្លែកអ្វី តែនៅទីនោះ គេបែរជាសម្រុកនាំគ្នាដណ្ដើមយករបស់ចាស់បាក់បែកស្អុយទៅវិញ។ នេះហើយគឺជាជីវិតដែលពឹងផ្អែកលើគំនរសំរាមនោះ!។
នៅទីនោះ បើប្រៀបធៀបជាមួយនឹងទីក្រុង វាគឺហាក់បីដូចជាឋាននរក តែសម្រាប់មនុស្សដែលគ្មានការងារធ្វើ និងគ្មានជម្រើសផ្សេង កន្លែងនោះបានប្រែទៅជាទីស្ថានមួយសំខាន់សម្រាប់ជីវិត និងអនាគតរបស់ពួកគេ។ ជុំវិញខ្លួន ដែលមានតម្រៀបការ៉ុងធំៗ ពី៤ ទៅ៥ និងកំពុងចំហមាត់រង់ចាំទទួលសំរាមអេតចាយចូល អ្នកស្រីសោម សឿន មានអាយុ៤៩ឆ្នាំដែលស៊ាំទៅនឹងការងារ និងក្លិននៅទីនោះ រយៈពេល ៣ឆ្នាំមកហើយនោះ បាននិយាយថា គាត់គ្មានគំនិតដើម្បីផ្លាស់ប្ដូរការងារថ្មីនោះឡើយ។ បើសិននៅមានគំនរសំរាមនេះទៀត គាត់នឹងនៅធ្វើជាមួយវាជារៀងរហូត ព្រោះមុខរបរនេះមិនសូវជាលំបាកសម្រាប់គាត់ទេ ហើយម្យ៉ាងទៀត វាមិនមានការចំណាយដើមទុនដូចជាការងារដទៃទៀតដែរ។
លោកស្វាយ លន ជាអ្នកគ្រប់គ្រងតំបន់សំរាមស្ទឹងមានជ័យ មានប្រសាសន៍ឱ្យដឹងថា : "អ្នករើសសំរាម គឺជាអ្នកខ្វះខាត ហើយបញ្ហាសំខាន់បំផុត ការខ្វះខាតរបស់អ្នករើសសំរាម គឺជាការខ្វះលុយតែប៉ុណ្ណោះ"។
ប្រជាជនរស់នៅលើគំនរសំរាមនេះបានជួបប្រទះនូវបញ្ហាជាច្រើន ដែលគេត្រូវប្រឈមមុខ គឺមានទាំងជីវភាព និងទាំងសុខភាព។ លូកដៃផ្ទឹះយកជំរដែលឋិតនៅមិនឆ្ងាយប៉ុន្មានពីកន្លែងអង្គុយដាក់ទៅក្នុងការ៉ុងដែលបញ្ឈរនៅក្បែរខ្លួន អ្នកស្រី ឆ្លៀតបន្តសំដីទៀតថា គាត់ក៏មានការព្រួយបារម្ភចំពោះបញ្ហាសុខភាពរបស់គាត់ដែរ ប៉ុន្តែទោះបីជាគាត់ខ្វាយខ្វល់ ក៏ប៉ុណ្ណឹង មិនខ្វាយខ្វល់ក៏ប៉ុណ្ណឹង។ មកដល់ត្រង់ចំនុចនេះ ភុន ង៉ែតដំឡើងសំឡេងខ្លាំងៗថា : "មិនរក ក៏ងាប់ រកសំរាម ក៏ងាប់ ដូច្នេះបណ្ដោយទៅតាមដំណើររបស់វាទៅចុះ"។ ឈរនៅក្បែរនោះដែរ លោកប៊ុន ម៉ៅ មានអាយុ ២៥ឆ្នាំ និងធ្វើការជាមួយសំរាមតាំងពីឆ្នាំ១៩៩១ មានការព្រួយបារម្ភ ដូចគ្នានឹងភុន ង៉ែត ដែរថា ការប្រកបការងារនៅទីនេះ គឺមានជួបនូវផលលំបាក តាំងពីដើមមកហើយ ទាំងបញ្ហាបរិស្ថាន និងសុខភាព។ លោកបន្ថែមថា ការប្រកបការងារនៅទីនេះ គាត់អាចផ្គត់ផ្គង់ជីវភាពរបស់គ្រួសារគាត់បានមែន តែបានបន្តិចបន្តួចតែប៉ុណ្ណោះ មិនសម្បូរហូរហៀរ ដូចគេនោះទេ។ ទោះបីជាការងារនេះគាត់ធ្វើយូរហើយក៏ដោយ តែគាត់នៅមានបំណងមួយថា ប្រសិនបើមានការងារផ្សេងប្រសើរជាងនេះ ហើយគាត់អាចធ្វើបាននោះ គាត់នឹងចាប់យកការងារថ្មីវិញ ប៉ុន្តែបើគ្មានការងារថ្មីទេ គាត់នៅតែប្រកបការងារនេះរហូត។ ក្នុងមួយថ្ងៃ ប៊ុន ម៉ៅ អាចរកចំណូលបានពី៧០០០-១២០០០រៀល ដោយអាស្រ័យលើឡានតិច ឬច្រើន។
លោកម៉ិច សុខា ជាប្រធានរបស់អង្គការមណ្ឌលកុមារដើម្បីសុភមង្គល ដែលជាអង្គការផ្ដល់កន្លែងស្នាក់នៅ អាហារ ការថែទាំសុខភាព ចំណេះដឹង និងវិជ្ជាជីវៈផ្សេងៗទៀតជាច្រើនដល់កុមារ។ លោកមានប្រសាសន៍ថា ក្មេងៗនៅទីនោះ បើពុំមានការជួយពីអង្គការផ្សេងៗនោះ ពួកគេនឹងជួបការលំបាកខ្លាំងពីព្រោះពួកគេឥតមានអ្វីសោះ។ លោកក៏បន្តថា ខ្លះមិន...

## ភ្នំសំរាមនៅស្ទឹងមានជ័យ

វាជាកន្លែងចោលសំរាមដ៏ធំនៅក្នុងទីក្រុងភ្នំពេញ ហើយក៏ជាលំនៅដ្ឋាន និងកន្លែងធ្វើការរបស់ប្រជាជនកម្ពុជាដ៏ច្រើនឥតគណនា។ វាជាកន្លែងប្រជុំដោយជនក្រីក្ររាប់រយនាក់មកពីបណ្ដាខេត្តផ្សេងៗ ហើយភាគច្រើនជាក្មេងស្វែងរកការងារនៅទីក្រុង។ ពួកគេស្វែងរករបស់របរគ្រប់ប្រភេទ ដែលជាប់នៅនឹងសំរាមដើម្បីយកលក់ ឬយកប្រើប្រាស់។

... បានទៅរៀន ខ្វះគ្មានអាហារបរិភោគ និងមិនមានការថែទាំសុខភាព និងការអប់រំដែលទាំងនេះជាបញ្ហាសំខាន់បំផុត។

នៅក្នុងទឹកមុខសញ្ជឹងគិតនិងភ្នែកសម្លឹងមើលទៅឆ្ងាយ ភុន ង៉ែត ហាក់ដូចជានៅមានទុក្ខកង្វល់ជាច្រើនក្នុងចិត្ត ដោយពុំមាននរណាអាចដឹងបាន។ រំពេចនោះ គាត់បញ្ចេញសំឡេងដោយសង្ឃឹមជានិច្ចថា: "ចំពោះអនាគតរបស់កូនខ្ញុំ ខ្ញុំមានការព្រួយបារម្ភចំពោះពួកគេខ្លាំងណាស់ តែខ្ញុំគ្មានសមត្ថភាពផ្តល់អនាគតដល់ពួកគេបានល្អទេ"។ ស្ត្រី វ័យ៤៥ឆ្នាំ រូបនេះបានបន្ថែមថា គាត់ពុំឱ្យកូនរបស់គាត់ប្រកបការងារនេះ ដូចគាត់ឡើយ ពីព្រោះអនាគតពួកគេនៅវែងឆ្ងាយតទៅទៀត តែគាត់មិនដឹងថា នឹងត្រូវធ្វើយ៉ាងណានោះទេ។

កំពុងអង្គុយអារយកដែកពីកាតាបកញ្ចាស់ពណ៌ក្រហមមួយ កុមារាមុត ស្រស់ អាយុ១៥ឆ្នាំ មកពីខេត្តកំពង់ធំ ដោយវាគ្មានការងារធ្វើ ទើបសម្រេចមកធ្វើការងារនៅទីនេះ ដើម្បីរកចំណូលជួយដល់គ្រួសារ។ មុត ស្រស់ អាចថាជាក្មេងមានសំណាងបន្តិចដែរ ពីព្រោះវាបានចូលសាលា ដូចជាក្មេងដទៃដែរ។ ប៉ុន្តែស្រស់ចង់ធ្វើការនៅរោងចក្រ គឺពុំចង់ធ្វើការងារនេះបន្តទៅទៀតនោះទេ។ ចំណែកឯកុមារីបាន ប៉ាច អាយុ១៣ឆ្នាំ ក៏មិនចង់ធ្វើការងារនេះរហូតនោះដែរ នាងនិយាយថា ទៅថ្ងៃអនាគត នាងចង់ធ្វើជាអ្នកចម្រៀង។

លោកម៉ិច សុខា មានការព្រួយបារម្ភចំពោះបញ្ហាអនាគតនៃក្មេងៗ ដែលធ្វើការនៅទីនោះ ក៏ដូចជាក្មេងៗ អនាថា ដែលពុំបានទទួលការអប់រំជាច្រើនទៀតដែរ។ លោកនិយាយថា បញ្ហាទាំងនេះ ធ្វើឱ្យមានការប៉ះពាល់ដល់ប្រទេសជាតិច្រើន ធ្វើឱ្យមានបញ្ហាហិង្សា និងអសន្តិសុខក្នុងសង្គម គឺដូចជា បើពួកគេគ្មានការងារធ្វើ ពួកគេចេះតែដើរលួច ឆក់ ប្លន់ ហិតការ៉ ជក់គ្រឿងញៀន និងបង្កើតជាក្រុមបងតូចបងធំ ដែលទាំងនេះគឺជាបញ្ហាអាចនឹងកើតមាន នៅក្នុងសង្គមកម្ពុជា។ ចំណុចមួយទៀតនោះ គឺភាពក្រីក្រក៏កាន់តែកើតមានឡើង ដែលបញ្ហានេះហើយធ្វើឱ្យសង្គមជួបនឹងវិបត្តិយ៉ាងធ្ងន់ធ្ងរ។

"បើកន្លែងនោះត្រូវបានរុះរើ ឬផ្លាស់ប្តូរ ខ្ញុំគិតថា ពួកគេនឹងទៅកន្លែងផ្សេង មានន័យថា ពួកគេនឹងទៅរស់តាមចិញ្ចើមថ្នល់ តាមសំណង់អនាធិបតេយ្យ ព្រោះពួកគេភាគច្រើនជាអ្នកអត់ដី" នេះជាសំដីព្រួយបារម្ភរបស់លោកម៉ិច សុខា។

### ទៅនៅកន្លែងថ្មី

យោងតាមផែនការថ្មីនៃអង្គការ Jica ទីលានថ្មីនឹងលែងឱ្យមានអ្នករើសសំរាមទៀតហើយ ដោយគម្រោងឱ្យពួកគេមួយចំនួនធ្វើជាកម្មករបើកឡាន និងខ្លះឱ្យធ្វើជាកម្មករផលិតជីកំប៉ុសកសិកម្ម។ កន្លែងថ្មីគឺនៅទួលប្រាសាទ ភូមិបាគូ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ តើពេលនោះជីវិតពួកគេនឹងទៅជាយ៉ាងណា បើគ្មានគំនរសំរាមនោះ ?

## អ្នកស្រីរ៉ូស: "ខ្ញុំគិតថា ក្នុងជីវិតរស់នៅ ទោះបីមានទុក្ខលំបាកយ៉ាងណា ក៏យើងនៅតែមានសង្ឃឹមដែរ"


Photo: DR

អ្នកស្រីរ៉ូស មកពីប្រទេសហុងកុង ជាអ្នកសម្របសម្រួលក្នុងក្រុមសន្តិវិនសេនដឺប៉ូល និងជាជំនួយការព្រះសហគមន៍កំពង់ចាម មានប្រសាសន៍ទាក់ទងនឹងសកម្មភាពជួយក្មេងអនាថា និងក្មេងរើសសំរាមថា: "សព្វថ្ងៃយើងឃើញនៅជុំវិញក្រុងកំពង់ចាម មានក្មេងរើសសំរាម និងក្មេងអនាថាជាច្រើនកំពុងប្រកបការងាររបស់ខ្លួនដោយមិនបានគិតពីការសិក្សា ឬអនាគតវែងឆ្ងាយទេ ដោយធ្វើយ៉ាងណាឱ្យតែអាចចិញ្ចឹមជីវិត និងជួយគ្រួសារបានមួយគ្រាៗប៉ុណ្ណោះ។ ក្មេងៗទាំងនោះមានសុខភាពមិនល្អ មិនបានចូលសាលារៀន និងខ្វះអាហារឧបត្ថម្ភផងដែរ។ ដូច្នេះយើងក៏ជួយឱ្យពួកគេទៅរៀន និងចង់បង្ហាញសេចក្តីស្រលាញ់ដល់ពួកគេដែរ"។

រៀងរាល់ថ្ងៃអាទិត្យ នៅព្រះសហគមន៍កំពង់ចាម ក្រុមសន្តិវិនសេនដឺប៉ូល បានណែនាំក្មេងៗទាំងនោះ ឱ្យយល់អំពីសុខភាពអនាម័យ លេងកំសាន្ត និងធ្វើបបរគ្រឿងសម្រាប់ពួកគេ ជួយពួកគេឱ្យមានសម្លៀកបំពាក់ សម្ភារៈសិក្សាផ្សេងៗ និងតាមដានការសិក្សារបស់គេផងដែរ។

បងស្រីរ៉ូស បន្តថា នៅក្នុងព្រះគម្ពីរសរសេរថា: "មនុស្សជា មិនត្រូវការគ្រូពេទ្យទេ មានតែអ្នកឈឺទេដែលត្រូវការគ្រូពេទ្យ"។ ដូច្នេះពេលបងប្អូនក្រីក្រជួបទុក្ខលំបាក ពួកគាត់ត្រូវការឱ្យមានអ្នកជួយ។ ខ្ញុំគិតថា ក្នុងជីវិត ទោះមានទុក្ខលំបាកយ៉ាងណា ក៏យើងនៅតែមានសង្ឃឹម។ ចំណែកអ្នកមានទ្រព្យសម្បត្តិ គេមិនត្រូវការ ឬប្រហែលមិនសូវចាប់អារម្មណ៍ឱ្យព្រះសហគមន៍ ឬអង្គការផ្សេងៗដើម្បីជួយគេដែរ។

ក្នុងព្រះគម្ពីរក៏មានចែងទៀតថា: "សូមបងប្អូនកុំយកចិត្តទុកដាក់នឹងទ្រព្យសម្បត្តិនៅលើលោកីយ៍នេះ យើងធ្វើយ៉ាងណាដើម្បីសន្សំទ្រព្យសម្បត្តិនៅស្ថានបរមសុខវិញ"។ ហេតុនេះក្នុងជីវិត យើងត្រូវធ្វើឱ្យគាប់ព្រះហឫទ័យព្រះជាម្ចាស់ ដូចជាបង្ហាញសេចក្តីស្រលាញ់ដល់អ្នកក្រីក្រ ធ្វើដូច្នេះមានន័យថា យើងកំពុងប្រមូលទ្រព្យសម្បត្តិដាក់ស្ថានបរមសុខ។ ព្រះជាម្ចាស់ឱ្យយើងស្រលាញ់ព្រះអង្គ និងស្រលាញ់បងប្អូនឯទៀត។

រហូតដល់ឥឡូវនេះ យើងបានកំពុងទាក់ទងជាមួយពួកគេប្រហែលជាងមួយឆ្នាំហើយ។ ពេលជួបគ្នា គេតែងតែសួរសុខទុក្ខយើង។ គេទទួលស្វាគមន៍យើង គេនៅចាំថាយើងមានពេលវេលាសប្បាយជាមួយគ្នាដែរ។

អត្ថបទដោយមុំ គន្ធា និងរ៉ូ បូរ៉ា





មណ្ឌលថែទាំកុមារ ដែលគ្រប់គ្រងដោយព្រះសហគមន៍កាតូលិកកំពង់ចាមក្រុង ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៤ ដែលផ្តួចផ្តើមគំនិតដោយបងស្រីរ៉ូស និងអ្នកស្រីឌុច វណ្ណី និងមានការចូលរួមជួយដោយព្រះសហគមន៍កំពង់ចាមផងដែរ។

# មណ្ឌលថែទាំកុមារ ព្រះសហគមន៍កំពង់ចាម


Photo: M. Kunthear

ថតរូបអនុស្សាវរីយ៍របស់ក្មេងៗ អ្នកគ្រប់គ្រង និងឪពុកម្តាយនៅមុខមណ្ឌលថែទាំកុមារ

សំឡេងស្រែកហៅកញ្ជ្រៀវ លាន់ឮកងរំពង នៅក្នុងផ្ទះតូចសង់ពីឈើលាបថ្នាំពណ៌ក្រហមអមដោយសួនផ្កានៅពីខាងមុខផ្ទះដ៏ល្អនេះ។ បើយើងឈានជើងចូលទៅក្នុងផ្ទះមួយនេះ យើងនឹងឃើញ នៅតាមជញ្ជាំង លំអដោយរូបថត ជាច្រើន ជាពិសេសនោះ គឺព្រះឆាយាល័ក្ខណ៍ព្រះមហាក្សត្រ សម្តេចតា សម្តេចយាយ រួមនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជាយ៉ាងល្អប្រណីតផងដែរ។ ក្មេងៗប្រមាណជា ២០នាក់ ជាងមានទាំងប្រុសស្រី ដែលមានអាយុពី៣-៥ឆ្នាំ កំពុងរត់លេងប្រដេញគ្នាយ៉ាងសប្បាយរីករាយ បន្ទាប់ពីពួកគេត្រូវបានគ្រូអនុញ្ញាតឱ្យឈប់សម្រាក ពីម៉ោងសិក្សា។ ប្រសិនបើយើងក្រលេកមើលនៅខាងមុខមណ្ឌល យើងនឹងឃើញនូវផ្លាកធំមួយដែលដាក់ភ្ជាប់នឹងរបងក្លោងទ្វារចូល ដែលសរសេរថា: "មណ្ឌលថែទាំកុមារព្រះសហគមន៍កាតូលិក"។

កំពុងអង្គុយចាំមើលក្មេងៗ ដើម្បីកុំឱ្យឈ្លោះប្រកែកគ្នា អ្នកស្រីឌុច វណ្ណី ជាអ្នកមើលការខុសត្រូវ ក្នុងមណ្ឌល បានមានប្រសាសន៍ថា: "គោលបំណងនៃការបង្កើតមណ្ឌលនេះឡើង គឺដោយសារឃើញអំពីបញ្ហាជីវភាពក្រីក្រ ហើយឪពុកម្តាយរបស់ពួកគេជាប់រវល់រកស៊ី។ ដូច្នេះយើងក៏ឱ្យពួកគេយកកូនមកទុកនៅទីនេះដើម្បីឱ្យពួកយើងមើលថែទាំឱ្យ"។ អ្នកស្រីបន្តទៀតថា ពីដំបូងឡើយ យើងជួលផ្ទះគេ ប៉ុន្តែក្រោយមកដោយមានការចាប់អារម្មណ៍ច្រើនពីឪពុកម្តាយក្មេង យើងក៏សម្រេចចិត្តទិញដី និងធ្វើផ្ទះដោយខ្លួនឯងដែលត្រូវចំណាយថវិកាជាច្រើន ដែលយើងបានទទួលនូវការឧបត្ថម្ភគាំទ្រ ពីសំណាក់ព្រះសហគមន៍កាតូលិកកំពង់ចាមក្រុង។

កំពុងឈរសម្លឹងទៅមើលកូនប្រុសតូច ដែលរត់លេងជាមួយមិត្តភក្តិរាងទៃទៀត អ្នកនាងសុធាវី អាយុ២៥ឆ្នាំ ដែលទើបតែបានយកកូនមកផ្ញើនៅមណ្ឌលនេះមានប្រសាសន៍ថា: "ខ្ញុំយកកូនមកដាក់ទីនេះដោយសារខ្ញុំមានការទុកចិត្តថា នៅទីនេះ គេអាចបង្រៀនកូនខ្ញុំឱ្យអាចចេះអក្សរបានខ្លះៗ និងដឹងអំពីរបៀបរបបផ្សេងៗទៀតផងដែរ។"

"នៅថ្ងៃអនាគត ខ្ញុំគិតថា មណ្ឌលនេះនឹងមានការរីកចម្រើនជាងនេះទៅទៀត ព្រោះឥឡូវនេះ មនុស្សភាគច្រើនមិនគិតថា យើងមានសាសនាផ្សេងគ្នានោះទេ។ ពួកគេទុកចិត្តមកលើយើង ម្យ៉ាងសព្វថ្ងៃ យើងមានបើកបណ្ណាល័យសម្រាប់ក្មេងថ្នាក់ទី២ និងទី៣ ផងដែរ ដោយយើងមានសៀវភៅឱ្យគេចូលអាន ហើយយើងឃើញថា គេមានការចាប់អារម្មណ៍ក្នុងការចូលរួមអានទៀតផង។ ដូច្នេះយើងក៏មាននូវឱកាសបង្ហាញពីអ្វីមួយដែលយើងចង់ធ្វើ និងអប់រំគេឱ្យចេះស្គាល់ពីសង្គមដើម្បីឱ្យគេងាយស្រួលក្នុងការរស់នៅពេលធំឡើង"។ នេះជាសំដីចុងក្រោយរបស់អ្នកស្រីវណ្ណី ដែលពោរពេញទៅដោយក្តីសង្ឃឹមជានិច្ច។

បច្ចុប្បន្ននេះ នៅក្នុងមណ្ឌល មានក្មេងប្រមាណជា ២៤នាក់ ដែលពួកគេមករៀននៅទីនេះជាទៀងទាត់ ដែលពីមុនមានប្រហែលពី ១៧-១៨នាក់ប៉ុណ្ណោះ។ ការចូលរៀននៅទីនេះមិនមានលក្ខខណ្ឌអ្វីសម្រាប់ឪពុកម្តាយទេ ដោយគ្រាន់តែសុំឱ្យពួកគេបង់ថវិកាខ្លះៗ ដែលមានតម្លៃថោកបំផុត ពី ១០០ ទៅ៥០០រៀលតែប៉ុណ្ណោះក្នុងមួយថ្ងៃ ប៉ុន្តែបើគ្មាន ក៏ពួកគេអាចនាំកូនមកចូលរៀនបានដែរ។ លើសពីនេះ មណ្ឌលមានផ្តល់ឱ្យក្មេងៗ ជាម្ហូបអាហារ ពីរពេល ក្នុង១ថ្ងៃ ដោយមានបបរព្រឹក និងបាយថ្ងៃត្រង់ ដែល១ថ្ងៃ មណ្ឌលត្រូវចំណាយជាមធ្យមសម្រាប់ក្មេងម្នាក់ចំនួន ៨០០រៀល។

មុំ គន្ធា

### មណ្ឌលថែក្មេង

មណ្ឌលនេះមានបង្រៀនជាស្រៈ អក្សរខ្មែរ ភាសាអង់គ្លេស និងបង្រៀនការធ្វើអនាម័យទៅតាមសមត្ថភាពរបស់ក្មេង ដែលពួកគេអាចទទួលយកបាន។

ជារៀងរាល់ថ្ងៃ មណ្ឌលនេះចាប់ផ្តើមបើកពីម៉ោង ៧ព្រឹក រហូតទៅដល់ម៉ោង ៤រសៀលដោយមានឧបត្ថម្ភជាអាហារសម្រាប់ក្មេងៗ ហូបផងដែរ។ មណ្ឌលនេះមានទីតាំងនៅ ភូមិអណ្តូងច្រោះ ឃុំអណ្តូងច្រោះ ខេត្តកំពង់ចាម។

ពេលដែលក្មេងមានអាយុ ៦ឆ្នាំ មណ្ឌលត្រូវបញ្ជូនពួកគេទៅរៀននៅសាលារដ្ឋវិញ។ ក្នុងមួយឆ្នាំ មណ្ឌលត្រូវចំណាយប្រមាណជា ២ពាន់ដុល្លារដើម្បីដំណើរការ។

# សេចក្ដីវេទនានៃមនុស្សគឺគ្មានដែនកំណត់

សេចក្ដីលំបាក អំណរសប្បាយរបស់មនុស្សម្នាក់ៗ គឺគ្មាននរណាម្នាក់អាចដឹង ឬកំណត់បានជាមុននោះទេ។ អ្វីដែលយើងជួបប្រទះចំពោះមុខ គឺយើងត្រូវយល់ព្រមទទួលយក ហើយវាជាកម្លាំងមួយក្នុងការឈានទៅរកភាពជោគជ័យផងដែរ។


Photo: DR

លោកអភិបាល អន់តូនីសាមី ស៊ូសៃរាជ ដែលឆ្លើយសំនួរទាក់ទងនឹងព្រះសហគមន៍

**សំណួរ :** ហេតុអ្វីព្រះយេស៊ូត្រូវសុគតនៅលើឈើឆ្កាង? ហេតុអ្វីបានជាព្រះអង្គមិនជ្រើសរើសយកវិធីផ្សេងដើម្បីសង្គ្រោះមនុស្សលោក?

**លោកអភិបាលអន់តូនី :** នៅលើឈើឆ្កាងជារបៀបសោយទិវង្គតរបស់ព្រះយេស៊ូ ដោយសារនៅសម័យព្រះយេស៊ូ ជនជាតិរ៉ូម៉ាំង ធ្លាប់ប្រើឈើឆ្កាងដើម្បីសម្លាប់ចោរ ឬជនឧក្រិដ្ឋរបស់គេ។ នេះជារបៀបនៃការសម្លាប់មនុស្ស ដែលអាក្រក់ជាងគេ ហើយក៏ជារបៀបកាចសាហាវជាងគេដែរ។ លោកយេស៊ូយល់ព្រមស្លាប់ តាមរបៀបអាម៉ាស់នេះ ក៏ជារបៀបដែលអាក្រក់បំផុត។ លោកម៉ូសេបានយករូបសត្វពស់ ដែលនៅជាប់លើឈើ ឱ្យប្រជាជនដែលពស់ចឹកមើល ហើយពួកគេក៏បានជា។ នេះគឺសំដៅទៅលើឈើឆ្កាងដែរ មានន័យថាវាក៏ទាក់ទងទៅនឹងគម្រោងការរបស់ព្រះជាម្ចាស់ម្យ៉ាង និងប្រជាប់ ដែលជនជាតិរ៉ូម៉ាំងធ្លាប់ប្រើ នៅឯសម័យព្រះយេស៊ូ ដើម្បីសម្លាប់មនុស្ស។ ដូចនេះព្រះយេស៊ូក៏យល់ព្រមក្នុងការស្លាប់តាមរបៀបអាក្រក់បំផុត គឺជាអ្វីដែលព្រះយេស៊ូទទួលបាននូវភាពអាក្រក់ដូចនេះ។ យើងក៏អាចទទួលបានដែរ វាមានន័យថា សេចក្ដីទុក្ខវេទនារបស់មនុស្សយើង គឺមិនមានព្រំដែននោះទេ តែយើងអាចទទួលបានទាំងអស់ លុះត្រាតែជំនឿរបស់យើងនៅជាប់នឹងព្រះយេស៊ូ។

**សំណួរ :** ហេតុអ្វីបានជាព្រះអង្គមិនទទួលយកការស្លាប់ដោយជ្រើសរើសយកវិធីផ្សេងពីនេះ?

**លោកអភិបាលអន់តូនី :** នេះគឺជាការពិតប្រាកដ នៅពេលដែលព្រះយេស៊ូទ្រង់ចូល ទៅក្នុងសួនច្បារគេតសេម៉ានី ចាប់ផ្ដើមអង្វរព្រះបិតា ព្រះយេស៊ូមិនចង់បានឈើឆ្កាងទេ គឺចង់បានរបៀបស្រួលជាងនេះទៀត។ នេះគឺជារបៀប ដែលព្រះយេស៊ូអង្វរព្រះបិតាថា តើលោកស្មានថាខ្ញុំត្រូវតែទទួលឈើឆ្កាងឬ? តើប្រេងល្វីងនេះខ្ញុំចោលបានទេ? នេះគឺជារបៀបដែលព្រះយេស៊ូអធិដ្ឋានជាមួយព្រះបិតា ដូចចង់បានរបៀបមួយស្រួលជាង។ នេះគ្រាន់តែមួយរយៈ ក្រោយមកព្រះអង្គមិនចាញ់ការល្បួងឡើយ ទ្រង់ក៏យល់ព្រមទទួល។ សម្រាប់យើងដូចគ្នាដែរ ក្នុងជីវិតរបស់យើង គឺយើងចង់បានអ្វី ដែលយើងចូលចិត្តមានការងាយស្រួល ប៉ុន្តែតាមពិតយើងពុំមែនជាម្ចាស់របស់ជីវិតយើងទាំងស្រុងនោះទេ។ យើងត្រូវទទួលការណ៍នេះនៅក្នុងជីវិតរបស់យើង។ ក្នុងជីវិតយើងជាគ្រិស្តបរិស័ទ គឺមានលក្ខណៈយល់ព្រមទទួល ទោះបីជាយើងយល់ព្រម ឬមិនយល់ព្រម គឺត្រូវតែទទួល ហើយនៅពេលយើងយល់ព្រម យើងនឹងមានកម្លាំងទទួល។

**សំណួរ :** តើប្រទេសអ៊ីស្រាអែលមានចម្ងាយប៉ុន្មានគីឡូម៉ែត្រពីប្រទេសកម្ពុជា? តើភូមិកំណើតរបស់ព្រះយេស៊ូមានឈ្មោះអ្វីដែរ?

**លោកអភិបាលអន់តូនី :** ប្រសិនជាយើងធ្វើដំណើរ ចេញពីប្រទេសកម្ពុជាតាមផ្លូវគោកដោយឆ្លងកាត់ប្រទេសថៃ ភូមា ឥណ្ឌាខាងជើង ប៉ាគីស្ថាន អាហ្គានីស្ថាន អ៊ីរ៉ាក់ និង ប្រទេសស៊ីរីនោះ ទើបយើងបានទៅដល់ប្រទេសអ៊ីស្រាអែល ហើយបើគិតជាប្រវែងនោះ គឺមានប្រហែល មួយម៉ឺនគីឡូម៉ែត្រ។ ភូមិកំណើតរបស់ព្រះយេស៊ូមានឈ្មោះ ភូមិអាប្រាហ៊ិម នៅស្រុកណាសារ៉ែត និងជាកន្លែងដែលព្រះយេស៊ូធំធាត់ឡើង។

មុំ គន្ធា

## ស្រាយចម្ងល់

ប្រសិនបើប្រិយមិត្តអ្នកអាន "អ្នកនាំសារ" មានចម្ងល់ ឬមានសំណួរទាក់ទងទៅនឹងព្រះសហគមន៍កាតូលិក ក៏ដូចជារឿងរ៉ាវ ដែលលោកអ្នកមិនទាន់យល់ច្បាស់អំពីព្រះជាម្ចាស់។ ប្រិយមិត្តអាចសរសេរជាសំណួរមកការិយាល័យអ្នកនាំសារ តាមរយៈលោកបូជាចារ្យ ឬទូរស័ព្ទមកលេខ: ០១៦ ៣២៦ ៧៣៧ ឬ ០១២ ៣៣៨ ៩៨៥។ យើងខ្ញុំនឹងបកស្រាយជូនលោកអ្នកតាមរយៈការអញ្ជើញលោកបូជាចារ្យនានានៃភូមិភាគទាំងបី។





# ចិញ្ចឹមពូជគោទឹកដោះ

សម្រាប់ប្រជាកសិករ ក្រៅពីការងារស្រែចំការរបស់ខ្លួន ការចិញ្ចឹមសត្វគឺជាការងារមួយដែរ។ ជាក់ស្ដែងប្រជាកសិករមួយចំនួននៅឃុំកោះក្របី ស្រុកក្បៀនស្វាយ ខេត្តកណ្ដាល បានចិញ្ចឹមពូជគោទឹកដោះដើម្បីរឹតទឹកដោះយកលក់ ដែលនេះអាចរកកម្រៃលើកស្ទួយជីវភាពឱ្យធូរស្បើយបានមួយកម្រិត។


លោកកែវ ស៊ុន

លោកកែវ ស៊ុន អ្នកសម្របសម្រួលសមាគមអ្នកចិញ្ចឹមគោទឹកដោះនៅកម្ពុជា បានមានប្រសាសន៍ឱ្យដឹងថា: ពូជគោទឹកដោះវាមានពីរ មានពូជ ជីស៊ី និងអាអេហ្វអេស។ ពូជអាអេហ្វអេស ផ្ដល់សាច់ផង និងទឹកដោះផង។ ចំណែកជីស៊ី ជាពូជទឹកដោះសុទ្ធ។ ពូជទាំងនេះត្រូវបានក្រុមហ៊ុនទឹកដោះគោ Nestle ធ្វើការនាំចូលមកផ្សព្វផ្សាយ ហើយបង្កាត់ជាមួយពូជគោនៅក្នុងស្រុក ដើម្បីឱ្យប្រជាកសិករខ្មែរយើងចិញ្ចឹម ចាប់តាំងពីឆ្នាំ ២០០០មកម្ល៉េះ។

ការចិញ្ចឹមគោទឹកដោះនេះ គឺគេត្រូវរក្សាយ៉ាងណាឱ្យសីតុណ្ហភាពរបស់វាបានត្រជាក់ជានិច្ច ពីព្រោះបើក្ដៅវាអាចបាត់បង់ទឹកដោះបាន។ ចំណែកការឱ្យចំណី គឺគេត្រូវការដាំស្មៅ ឬច្រូតស្មៅដុះតាមធម្មជាតិ ឱ្យវាស៊ី តែសំខាន់ គឺត្រូវឱ្យវាស៊ីឱ្យបានច្រើន និងទៀងទាត់។ បន្ថែមពីលើស្មៅ ដែលគោស៊ី គេអាចបំប៉នគោឱ្យមានសុខភាពល្អ ធំធាត់ និងផ្ដល់ទឹកដោះច្រើន និងមានជាតិវីតាមីនដោយផ្ដល់អាហារដែលមានជាតិប្រូតេអ៊ីន និងជាតិរ៉ែ។ អាហារប្រូតេអ៊ីនក្នុងស្រុក គេច្រើនតែធ្វើអំពីសណ្ដែកសៀង។ ចំណែកអាហាររ៉ែ មានដូចជា ពោតកន្ទក់ ស្ករត្នោត និងដើមចេកជាដើម ហើយគេត្រូវរៀនក្បួនផ្សំវាពីអ្នកជំនាញកសិកម្ម។ ចំពោះទឹកផឹក ក៏គេត្រូវធ្វើឱ្យវាមានអនាម័យដែរ ពុំចេះតែឱ្យវាផឹកទឹកត្រពាំង ថ្លុក ដែលល្អក់កករនោះទេ។ ម្យ៉ាងទៀតចំពោះទ្រុងវិញ ត្រូវតែធ្វើឱ្យមានលក្ខណៈទូលាយ មានខ្យល់ចេញចូលគ្រប់គ្រាន់ ពិសេសគឺត្រូវរក្សាអនាម័យវា ឱ្យបានជាប់ជាប្រចាំផងដែរ។ ចំណុចដែលសំខាន់ដែរនោះ គឺគេត្រូវយកចិត្តដាក់ទុកដល់សុខភាពគោ។ បើវាមានជំងឺ ដូចជាបួសថ្លើម បួសក្ដាម អុជក្ដាម ឬក៏រាគនោះ គេត្រូវរកពេទ្យសត្វឱ្យមកព្យាបាលជាបន្ទាន់។


Photos: P. Samphy

ការរឹតដោះគោត្រូវធ្វើឡើងនៅពេលព្រលឹមដើម្បីឱ្យបានទឹកដោះសុទ្ធល្អ

សម្រាប់គោទឹកដោះ នៅពេលវាកើតកូនមួយ វាចាប់ឱ្យទឹកដោះ។ ហើយជាធម្មតា គេអាចរឹតបាន រយៈពេលប្រហែលជា ៣០០ថ្ងៃ ឬប្រមាណ ១០ខែបន្ទាប់មក។ គោបង្កាត់នៅជំនាន់ទីមួយ គឺគេអាច រឹតបានពី៦ ទៅ៧លីត្រ ក្នុងមួយថ្ងៃ តែគេច្រើនយកតែប្រាំលីត្រទេដោយទុកឱ្យកូនវាបៅខ្លះ។

លោកកែវ ស៊ុន គូសបញ្ជាក់ថា នាពេលសព្វថ្ងៃនេះ ទឹកដោះគោស្រស់ ដែលសមាជិកសមាគមផលិតបាន គឺមានតិចតួចណាស់។ ប៉ុន្តែឱ្យតែផលិតបាន គឺមានទីផ្សារចាំទទួលទិញតែម្ដងដោយគាត់ជាអ្នកចាំយកទៅដាក់នៅតាមភោជនីយដ្ឋាននានា នៅទីក្រុងភ្នំពេញ ដូចជា ភោជនីយដ្ឋានបារាំង ឥណ្ឌា ខ្មែរ។ រីឯជនបរទេសក៏គេចូលចិត្តទឹកដោះគោស្រស់ៗដែរ។

លោករ៉េន វ៉ាត់ ជាប្រធាន សមាគមអ្នកចិញ្ចឹមគោទឹកដោះនៅកម្ពុជា បានមានប្រសាសន៍ថា ចំពោះការចិញ្ចឹមគោទឹកដោះនេះ បើយើងថែទាំខ្លាំង វាក៏ឱ្យទឹកដោះច្រើនដែរ។ ការចិញ្ចឹមនោះទៀតសោត ក៏វាមិនមានការលំបាកប៉ុន្មានដែរ។ មិនត្រឹមតែប៉ុណ្ណោះ វាក៏អាចរកចំណូលឱ្យគាត់បន្ថែមពីលើការងារផ្សេងៗ មួយថ្ងៃបានប្រហែលជា ៥ដុល្លារដែរ។

ផាត សំភី

## ការចាប់ផ្ដើម

សមាគមអ្នកចិញ្ចឹមគោទឹកដោះចាប់ផ្ដើមបង្កើតឡើងនៅឆ្នាំ២០០១។ សព្វថ្ងៃ មានសមាជិក ២១នាក់។ បើប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ចូលជាសមាជិក ឬចិញ្ចឹមប្រភេទគោនេះ អាចសាកសួរព័ត៌មានពីលោកកែវ ស៊ុន អ្នកសម្របសម្រួលសមាគម តាមរយៈទូរស័ព្ទលេខ: ០១២ ៨៧៣ ១៣៥។

## កូនកំប្រុកខាងក្រោមកំពុងឡើងបេះផ្លែមង្ឃុត។ តើវាកំពុងបេះដាក់ក្នុងអ្វី? សូមគូសភ្ជាប់ពីលេខ១ ដល់២៥ ប្រិយមិត្តនឹងដឹងមិនខាន។



### សុភាសិតគួរពិចារណា!

- កងទ័ពក្តាន់ រមាំង ដែលមានខ្លាមួយជាមេដឹកនាំខ្លាំងពូកែជាងទ័ពខ្លា ដែលមានក្តាន់ រមាំងមួយជាមេដឹកនាំ។

  ក្រិក

- ពិភពលោក គឺជារបស់អ្នកដែលហ៊ាន។ មេឃ គឺជារបស់អ្នកដែលតតាំងប្រឆាំងនឹងមេឃ។

  បាស្គ៏

- កំហុសដែលអាក្រក់សាហាវបំផុត គឺការមិនស្គាល់កំហុសទាំងនោះ។

  ឡាតាំង

- បើគ្មានប្រាក់សម្រាប់ជួលទេ ស្បង់ក៏គ្មានដែរ។

  ក្រិក

- សេរីភាពគឺជាសិទ្ធិនឹងធ្វើអ្វីដែលច្បាប់អនុញ្ញាត។

  បារាំង

- ត្រូវធ្វើអ្វីដែលត្រូវធ្វើ មានរឿងរ៉ាវអ្វីក៏មានចុះ។

  បារាំង

- ច្បាប់ធូរពេកគ្មាននរណាគោរព។ ច្បាប់តឹងពេកគ្មាននរណាអនុវត្ត។

  អាមេរិកាំង



# ជំងឺហឺត

**ការថែទាំសុខភាពគឺចាំបាច់បំផុតដើម្បីរស់នៅឱ្យមានសុភមង្គល។ មិនថាជំងឺណា ឬជំងឺណាទេ តែងផ្តល់ទុក្ខទោសមិនលែង ដូចជា ជំងឺហឺតដែលត្រូវការព្យាបាលយូរ ឬក៏មួយជីវិតយើងតែម្តង។**

ហឺតជាជំងឺផ្លូវដកដង្ហើម និងមាន ២យ៉ាង។ ទី១ កើតឡើងដោយសារការប្រតិកម្ម (Allergie)។ អ្នកជំងឺ មានប្រតិកម្មជាមួយអាកាសធាតុ សត្វ រោមសត្វ ឬក៏រុក្ខជាតិ ដែលនាំឱ្យហឺត។ ជំងឺហឺតម្យ៉ាងទៀតកើតឡើងដោយសារពួកមេរោគដែលមានពពួកវីរុស និងបាក់តេរី ដែលធ្វើឱ្យយើងរលាកទងសួត ត្បៀតទងសួត ដែលនាំឱ្យយើងកើតជំងឺហឺតដែរ។

លោកវេជ្ជបណ្ឌិតឈៀ គន្ធារី មានប្រសាសន៍ថា អ្នកជំងឺហឺតមានរោគសញ្ញា ដូចជា ហត់ដង្ហក់ លំបាកដកដង្ហើម និងក្អកមានស្លេស្មជាដើម។ គេមានដង្ហើម ដូចជាឆ្មារយំ ឮសូរងឺតៗ តែពុំមានក្តៅខ្លួនទេ។ ប៉ុន្តែ ជំងឺហឺតបង្កឡើងដោយមេរោគគឺមានរោគសញ្ញាដូចគ្នា និងថែមទាំងក្តៅខ្លួនទៀត។

ពេលមនុស្សកើតហឺតកាន់តែយូរនោះ ការត្បៀតទងសួតក៏កាន់តែខ្លាំង ដែលនេះធ្វើឱ្យផ្លូវដកដង្ហើមគេខ្សោយខ្លាំងមែនទែន និងធ្វើឱ្យខ្សោយបេះដូងផ្នែកខាងស្តាំផងដែរ។ ជំងឺនេះអាចបណ្តាលឱ្យបាត់បង់ជីវិតបាន បើពេលនៅស្រាល គេមិនព្យាបាល និងទុកឱ្យធ្ងន់ទៅៗ តាមការវិវត្តន៍របស់វានោះ។

លោកវេជ្ជបណ្ឌិតឈៀ គន្ធារី ក៏គូសបញ្ជាក់ថា ការព្យាបាលជំងឺហឺតគឺធ្វើទៅតាមរោគសញ្ញារបស់វា។ តួយ៉ាងបើសិនជាហត់ខ្លាំងដោយត្បៀតទងសួត គេឱ្យថ្នាំធ្វើឱ្យទងសួតបើក ឬត្រូវបញ្ចូលអុកស៊ីសែន។ តែអ្នកជំងឺត្រូវមកជួបនឹងគ្រូពេទ្យឯកទេសដើម្បីងាយស្រួលព្យាបាល។ ការព្យាបាលជំងឺហឺតវាមិនអាចកំណត់បានទេ គេគ្រាន់តែព្យាបាលវាឱ្យធូរស្រាលមួយរយៈៗដែលត្រូវព្យាបាលមួយជីវិត។ ប៉ុន្តែជំងឺហឺតដែលកើតពីមេរោគ គេអាចព្យាបាលឱ្យជាសះស្បើយបាន។

ជំងឺហឺតកើតមានលើគ្រប់វ័យទាំងអស់ មានក្មេងវ័យ ជំទង់ ឬមនុស្សចាស់។ ប៉ុន្តែ បើវាកើតលើមនុស្សក្មេង ឬចាស់ជរានោះ ជំងឺហឺតច្រើនតែមានសភាពធ្ងន់ធ្ងរខ្លាំង។

ផាត សំភី



Photo: P. Samphy

វេជ្ជបណ្ឌិតឈៀ គន្ធារី នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

### ដើម្បីបង្ការខ្លួន

នៅរដូវត្រជាក់ បើយើងកើតផ្តាសាយ ត្រូវផឹកថ្នាំការពារខ្លួន។ បើយើងដឹងថា មានប្រតិកម្មជាមួយអ្វី ដូចជាសត្វអ្វី ធូលីដី ឬលំអងផ្កាអ្វីនោះ យើងកុំទៅក្បែររបស់ទាំងនោះ។



# វិស្វករជនបទ

**វិស្វករមានច្រើនប្រភេទ ដូចជា វិស្វករអគ្គិសនី អេឡិចត្រូនិក មេកានិក-ល- តែសម្រាប់ការកសាងសំណង់ផ្សេងៗ គឺត្រូវតែមានការចូលរួមពីវិស្វករទេពកោសល្យជនបទដោយខ្វះមិនបាន។**



Photo: Kimsay

វិស្វករអាចគណនាគ្រឹះសំណង់មុននឹងចុះធ្វើការនៅលើការដ្ឋាន

លោកអ្លូង គីមសាយ វិស្វករទេពកោសល្យជនបទ បានមានប្រសាសន៍ថា ការងាររបស់យើង ជាវិស្វករ គឺសំដៅទៅលើការប្រើចំណេះទ្រឹស្តី ដើម្បីសាងសង់សំណង់ផ្សេងៗ មានដូចជាអគារ ស្ពាន ផ្លូវថ្នល់ និងសំណង់ធារាសាស្ត្រជាដើម។

លោកគីមសាយ បានបរិយាយដោយត្រួសៗថា សម្រាប់ការកសាងសំណង់មួយ មុនដំបូងគេត្រូវតែមើលទៅលើដី និងទីតាំង។ ទីពីរគេត្រូវមើលទៅលើប្រភេទដី តើដីអាចទ្រទម្ងន់បានប៉ុន្មាន? បន្ទាប់មក គេក៏ត្រូវសួរថា តើម្ចាស់សំណង់ចង់បានសំណង់នោះតូច ឬក៏ធំ និងរឹងមាំយូរប៉ុណ្ណា រួចយកផ្គូផ្គងនិងថវិកាម្ចាស់សំណង់។ បើគាត់មានថវិកាច្រើន គេក៏អាចសាង សង់សំណង់បានកាន់តែរឹងមាំ និងគង់វង្សយូរអង្វែង។

លោកបន្តថា សង់សំណង់មួយត្រូវមានវិស្វករជំនាញផ្សេងៗ ដូចជា វិស្វករអគ្គិសនី វិស្វករមេកានិក ឬវិស្វករបណ្តាញទឹកភ្លើង-ល-។ វិស្វករទាំងនេះធ្វើការជាមួយគ្នានិងទាក់ទងគ្នាទៅវិញទៅមកជានិច្ច។ ម្យ៉ាងវិញទៀត ក្នុងនាមជាវិស្វករ បើយើងចង់ឱ្យការងាររីកចម្រើន យើងត្រូវតែរៀនតាមបទពិសោធន៍ពីវិស្វករធំៗ ដែលគាត់បង្ហាញនៅនឹងការដ្ឋាន។

វិស្វករទេពកោលសល្យជនបទ អាចរកចំណូលបានតិច ឬក៏ច្រើន គឺអាស្រ័យលើក្រុមហ៊ុន។ ក្រុមហ៊ុនខ្លះឱ្យប្រាក់ខែជាស្តង់ដារ។ ចំណែកក្រុមហ៊ុនខ្លះឱ្យតម្លៃទៅតាមសមត្ថភាព។

លោកអ្លូង គីមសាយ និយាយថា នាសព្វថ្ងៃនេះ បើតាមដឹងវិស្វករចេញធ្វើដំបូង បានប្រាក់ខែចន្លោះពី ១៨០ ទៅ៣០០ ដុល្លារ។ ប៉ុន្តែ សម្រាប់អ្នកមានបទពិសោធន៍ ១០ឆ្នាំ ឡើងទៅយ៉ាងហោចណាស់ក៏បាន ៥០០ដុល្លារឡើងដែរ។

បើយើងចង់ក្លាយខ្លួន ជាវិស្វករទេពកោសល្យជនបទ យើងអាចទៅរៀននៅសាលារដ្ឋដោយការប្រឡងចូល ឬទៅរៀននៅសាលាឯកជនដោយការបង់ថ្លៃជាដើម។ ប៉ុន្តែទោះបីជាយ៉ាងណា យើងត្រូវរៀនឱ្យបានពូកែនៅសាលាចំណេះទូទៅលើមុខវិទ្យាសាស្ត្រ មានគណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យាជាដើម ដើម្បីងាយស្រួលពេលរៀននៅឯមហាវិទ្យាល័យ។ ចំណែកភាសាបរទេសមានអង់គ្លេស និងបារាំង គឺមានសារៈសំខាន់ណាស់ដែរ ព្រោះឯកសារសម្រាប់និស្សិតធ្វើការស្រាវជ្រាវភាគច្រើនសុទ្ធតែជាភាសាបរទេស។

ផាត សំភី

### សាលារៀន

យើងអាចរៀនជំនាញវិស្វករនៅឧត្តមសិក្សា ដោយការប្រឡងចូល ឬបង់លុយ មានដូចជា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ITC តាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី ទូរស័ព្ទ : ០២៣ ៨៨០៣៧០។ វិទ្យាស្ថានពហុបច្ចេក-ទេសព្រះកុសុមៈនៅផ្លូវសហព័ន្ធរុស្ស៊ី ទូរស័ព្ទ : ០២៣ ៣៣៨១៩៤។ សកលវិទ្យាល័យនរតុន ផ្លូវ១១៨ ទូរស័ព្ទ : ០២៣ ៩៨២១៧៧។

# លោកអ៊ុន ស៊ុនៈ “ក្លាយពីព្រះសង្ឃពុទ្ធសាសនាមកជាសង្ឃកាតូលិក”



Photo: H. Soktheary

លោកបូជាចារ្យអ៊ុន ស៊ុន នៅព្រះវិហារផ្សារតូច

**លោកអ៊ុន ស៊ុន ជាបូជាចារ្យខ្មែរដែលស្ម័គ្រចិត្តបម្រើព្រះសហគមន៍អស់រយៈជាង ៥ឆ្នាំមកហើយ។ លោកមិនដែលពោលនូវពាក្យថា ខ្ជិលមួយវិនាទីណាឡើយ។**

ក្រោយពីចាកចេញពីប្រទេសខ្មែរ អស់រយៈពេល ៣ឆ្នាំ បូជាចារ្យអ៊ុន ស៊ុន បានចូលបួសធ្វើជាសង្ឃនៅអាយុ១៥ឆ្នាំ តាំងពី១៩៧៤ នៅប្រទេសថៃ។ ការដែលលោកសម្រេចចិត្តបួសជាព្រះសង្ឃគឺក្នុងគោលបំណង ២យ៉ាងៈ ទីមួយ គឺដើម្បីទទួលការប្រៀនប្រដៅពីព្រះពុទ្ធសាសនា។ ទីពីរដើម្បីសងគុណឪពុកម្ដាយ។ លោកបូជាចារ្យរូបនេះ ក៏បានមានប្រសាសន៍ថាៈ “ជីវិតរបស់ខ្ញុំពេលនោះ មានអំណរសប្បាយខ្លាំងមែនទែន ដោយបានរៀនធម៌ និងគោរពទៅតាម គណៈមហានិកាយ”។ លោកបូជាចារ្យអតីតព្រះសង្ឃនៃពុទ្ធសាសនារូបនេះ ពុំមែនបួសជាសង្ឃ នៅប្រទេសកម្ពុជាទេ គឺលោកបួសនៅប្រទេសថៃ បន្ទាប់ពីលោកត្រូវភៀសខ្លួនចេញពីស្រុកខ្មែរក្រោមរបបប៉ុលពត ដែលលោកបានឆ្លងកាត់របបនេះតែ ៣ខែប៉ុណ្ណោះ។

នឹករលឹកទៅដល់អតីតកាល លោកបន្តថា លោកកាន់សីល៥ ដែលលោកត្រូវសិក្សាឱ្យស្គាល់ពីអំពើល្អ កុំប្រព្រឹត្តអំពើអាក្រក់។ លោកបន្ថែមក្នុងទឹកមុខស្រពោនថា ពេលរស់នៅជាមួយសង្ឃដទៃៗទៀតលោកក៏ទទួលបាននូវការមើលងាយ ដោយសារតែលោកគឺជាជនជាតិខ្មែរ។

“នៅឆ្នាំ១៩៧៩ ប្រជាជនខ្មែរដែលភៀសខ្លួន នៅស្រុកថៃ ត្រូវគេប្រមូលឱ្យចូលជំរំ។ ពេលនោះខ្ញុំក៏បានសឹក បន្ទាប់ពីដាក់ពាក្យទៅនៅស្រុកក្រៅ។ ក្រោយមកខ្ញុំរស់នៅជំរំមួយឆ្នាំ ដើម្បីរៀនភាសាដោយមិនដឹងថានឹងទៅនៅប្រទេសណាទៀតនៅឡើយទេ” លោកបូជាចារ្យស៊ុនបានបន្ថែម។

មានពេលមួយនោះមិត្តរបស់លោកប្រាប់ថា មានសាសនានៃសេចក្ដីស្រឡាញ់គេមកជួយ តែលោកព្រងើយកន្តើយដោយឆ្លើយតបទៅគេវិញថាគ្មានសាសនាណាមួយ ល្អជាងសាសនាព្រះពុទ្ធនោះទេ ពីព្រោះយើងមាននិព្វាន ដូច្នេះលោកក៏តែងមើលងាយចំពោះសាសនាផ្សេងៗ ដែរ។

បន្ទាប់ពីរស់នៅក្នុងជំរំមួយរយៈ លោកបូជាចារ្យអ៊ុន ស៊ុន ក៏ធ្វើដំណើរទៅដល់ប្រទេសកាណាដា។ នៅទីនោះលោកក៏បានចូលរៀនអប់រំជំនឿដោយគ្រាន់តែចង់ស្គាល់ព្រះយេស៊ូប៉ុណ្ណោះ។ ម្ដាយធម៌លោកតែងអានអត្ថបទ ព្រះគម្ពីរ ឱ្យលោកស្ដាប់ និងលើកទឹកចិត្តឱ្យរៀនអប់រំជំនឿ។ នៅក្នុងការរៀនអប់រំជំនឿនៅទីនោះ គេមានចាក់រឿង សន្តនិងសន្តីជាច្រើន ដែលជាគំរូដល់អ្នកជឿ។ លោកបន្តថា នៅក្នុងចំណោមរឿងជាច្រើន លោកពេញចិត្តរឿងសន្តដានីញ៉ែល ដែលគាត់សុខចិត្តលះបង់ចោលអ្វីៗដែលខ្លួនមាន រួចទៅបម្រើអ្នកដទៃ។

លោកបន្តថាៈ “ជីវិតមានព្រះវិញ្ញាណជាអ្នកបំភ្លឺក្នុងបេសកកម្មរបស់ព្រះជាម្ចាស់ មិនមែនអ្វីដែលយើងមានទេ។ ខ្ញុំអរគុណព្រះជាម្ចាស់សម្រាប់ថ្ងៃនេះ ដែលឱ្យខ្ញុំមានឱកាសអង្គុយក្នុងការិយាល័យ និងមានខោអាវស្អាត ដែលខ្ញុំមិនដែលស្រមៃ”។

ហ៊ូ សុខធារី

## ព្រឹត្តិការណ៍នឹងមាន!

- រៀងរាល់ដើមខែ : កិច្ចសំណេះសំណាល និងស្រស់ស្រូបអាហារពេលព្រឹកជាមួយគ្រូគង្វាលនៅព្រះសហគមន៍កំពង់ចាម។
- រៀងរាល់ថ្ងៃសៅរ៍ : ម៉ោង ៤រសៀល ក្រុមសង្គហៈនៃព្រះសហគមន៍សៀមរាប ចុះសួរសុខទុក្ខអ្នកជំងឺនៅតាមមន្ទីរពេទ្យ។
- ក្នុងអំឡុងខែកញ្ញា : ព្រះសហគមន៍សៀមរាបរៀបចំប្រក់ដំបូលផ្ទះពីរ ជូនដល់ចាស់ជរាពីរនាក់ដែលមានជីវភាពក្រីក្រ។
- ពីថ្ងៃទី១៧-១៩ កញ្ញា : សិក្ខាសាលាលោក-អ្នកគ្រូមត្តេយ្យចំនួន ៤០នាក់ មកពីព្រះសហគមន៍ចំការទៀង និងមានការចូលរួមពីគ្រូនៃព្រះសហគមន៍កំពង់ចាមផងដែរ ដែលធ្វើនៅក្រុងកំពង់សោម។
- ថ្ងៃទី១៩ កញ្ញា : ក្រុមអន្តរនិកាយគ្រិស្តសាសនាធ្វើទស្សនកិច្ចនៅព្រះសហគមន៍កាតូលិកចាស់នៅព្រះសហគមន៍កំពង់ចាម។
- ២អាទិត្យមុនបុណ្យភ្ជុំបិណ្ឌ : គ្រិស្តបរិស័ទនៅព្រះសហគមន៍ចំណោម និងបាត់ដំបងរួមគ្នាចែកជាវេនកាន់បិណ្ឌនៅក្នុងព្រះវិហារព្រះសហគមន៍។
- ថ្ងៃទី២២ កញ្ញា : ពិធីបុណ្យភ្ជុំបិណ្ឌ។
- ពីថ្ងៃទី២៣-២៤ កញ្ញា : មហាសន្និបាត ៤៥០ឆ្នាំ នៃព្រះសហគមន៍កាតូលិករបស់យុវជនកំពត និងចំការទៀង ចំនួន ២០០នាក់ ដែលធ្វើនៅចំការទៀង។
- ថ្ងៃទី២៨ កញ្ញា : បវេសនកាលថ្មីនៅមណ្ឌលនិស្សិតក្រុងកំពង់ចាម។
- ពីថ្ងៃទី១-៣ តុលា : មានសិក្ខាសាលាការ៉ូល និងសេដ្ឋា ជាមួយនិងឪពុកម្ដាយរបស់យុវជននៅកំពង់ចាម ដែលរិះគិតអំពីរបៀបរស់នៅជាគូស្រករ។
- ថ្ងៃទី២ តុលា : បើកឆ្នាំសិក្សាថ្មី នៅសាលាសន្តហ្វ្រង់ស្វ័រ ចំការទៀង។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៩២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រងៈ លោកអភិបាល អេមីល ដេតម្ប អគ្គនាយកៈ លោកបូជាចារ្យ ហៃរណាន់ ពីនីយ៉ា